ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិរបបសន្តិសុខសង្គម
លេខ : ០៤/០៩ ប.ស.ស

# សេចក្ដីជូនដំណឹង

ដើម្បីធ្វើអោយដំណើរការអនុវត្តន៍ផ្នែកហានិភ័យការងារទទួលបានលទ្ធផលល្អ បេឡាជាតិរបបសន្តិសុខសង្គមសូមជម្រាបជូនដំណឹងដល់អស់លោក-លោកស្រីជានិយោជកឬម្ចាស់សហគ្រាស ឱ្យបានជ្រាបថា : រាល់ចម្ងល់ដែលពាក់ព័ន្ធនឹងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ជាពិសេសផ្នែកហានិភ័យការងារ **ប.ស.ស** នឹងបើកឱ្យមានវេទិកា**សំនួរចម្លើយ** ទាក់ទងនឹងបញ្ហានេះ **រៀងរាល់ថ្ងៃព្រហស្បតិ៍ (ថ្ងៃធ្វើការ) ចាប់ពីវេលាម៉ោង ៨ និង៣០ នាទី ដល់ម៉ោង១១ និង៣០ នាទីព្រឹក នៅសាលប្រជុំធំជាន់ទី៣ នៃអាគារបេឡាជាតិរបបសន្តិសុខសង្គម ដែលស្ថិតនៅអាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធ រុស្ស៊ី សង្កាត់ ទឹកល្អក់១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ (ក្នុងបរិវេណទីស្ដីការក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ)** ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមអស់លោក-លោកស្រី ដែលជានិយោជក ឬម្ចាស់សហគ្រាស មេត្តាជ្រាបជាព័ត៌មាននិងចូលរួមស្វែងយល់តាមកម្មវិធីកំបីខាន។

សូមអស់លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩

**នាយក**

អ៊ុក សមវិទ្យា

លេខទូរស័ព្ទ : ០២៣ ៨៨ ២៦ ២៣ / ០២៣ ៨៨ ២៤ ៣៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**បេឡាជាតិរបបសន្តិសុខសង្គម**
លេខ : ០៣/០៩ ប.ស.ស

# សេចក្តីជូនដំណឹង

បេឡាជាតិរបបសន្តិសុខសង្គម សូមជំរាបជូនដំណឹងដល់អស់លោក-លោកស្រី ជានិយោកជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន កម្មករនិយោជិតទាំងអស់ ឱ្យបានជ្រាបថា : បេឡាជាតិរបបសន្តិសុខសង្គម សម្រេចធ្វើការផ្លាស់ប្តូរលេខទូរស័ព្ទថ្មី ដូចខាងក្រោម : សម្រាប់ **( ការិយាល័យបញ្ជិកា និងភាគទាន) ០២៣ ៨៨ ២៦ ២៣** និង **( ការិយាល័យ អធិការកិច្ច និងកិច្ចការនីតិកម្ម) ០២៣ ៨៨ ២៤ ៣៤** ចំពោះលេខ ( ~~០២៣ ៧២ ៥០ ៩២ / ០២៣ ៧២ ៣២ ១២~~) ត្រូវបានឈប់ប្រើដោយមូលហេតុ ប.ស.ស បានប្តូរទីតាំងមកកន្លែងថ្មី។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមអស់លោក-លោកស្រី ដែលជានិយោជក ឬម្ចាស់សហគ្រាសគ្រឹះស្ថាន និងកម្មករ និយោជិត មេត្តាជ្រាបជាព័ត៌មាន។

សូមអស់លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩
**នាយក**

អ៊ុក សំវិទ្យា